ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៦២៤៧ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៧

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការកំណត់តម្លៃអាជ្ញាប័ណ្ណ ភាពយន្ត និងវីដេអូ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## និង

## រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /០៧០៤ /០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់រដ្ឋធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ /១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩២ /០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ ០១ /នស/៩៣ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ១៩៩៩ ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យ ប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០២

និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០០៦

- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និង កែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- អនុវត្តតាមអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០០០ ស្តីពីការគ្រប់គ្រងត្រួតពិនិត្យសិល្បៈភាពយន្ត និងវីដេអូ
- អនុវត្តតាមអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- អនុវត្តតាមបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ ០៤ បប ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- អនុវត្តតាមប្រកាសលេខ ០០៤ សហវ.មប្រក ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- អនុវត្តតាមសារាចរណែនាំលេខ ០០២ សហវ.ម ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩៦ ស្តីពីវិជ្ជទេយ្យចំណូល
- បានឃើញលិខិត លេខ ១១៦៤ សជណ.អវ ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០០៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការអនុញ្ញាតកែសម្រួលកម្រៃអាជ្ញាប័ណ្ណ និងកម្រៃរដ្ឋបាល ដែលក្រុមហ៊ុនផលិតកម្ម ឬ រូបវន្តបុគ្គលដែលធ្វើផលិតកម្ម ភាពយន្ត ឬ ផលិតកម្មវីដេអូ ត្រូវបង់ជូនក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញសារាចរណែនាំលេខ ០៧ សរណ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០០ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ លើការអនុវត្តអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការគ្រប់គ្រងត្រួតពិនិត្យសិល្បៈភាពយន្ត និង វីដេអូ
- តាមការចាំបាច់របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## សម្រេច

**ប្រការ ១ :** អនុញ្ញាតឱ្យនាយកដ្ឋានសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ កំណត់កម្រៃលើអាជ្ញាប័ណ្ណ និងបន្តសុពលភាពអាជ្ញាប័ណ្ណ អនុញ្ញាតថត សេវាពិនិត្យអត្ថបទនិពន្ធ និងពិនិត្យខ្លឹមសាររូបភាពពាក់ព័ន្ធនឹងវិស័យភាពយន្ត និងវីដេអូ ដែលមានវិសាលភាពចំពោះ :

- រាល់ក្រុមហ៊ុន ផលិតកម្មភាពយន្ត វីដេអូនៅក្នុងប្រទេស និង ក្រុមហ៊ុនបរទេស ។
- រាល់ផលិតករក្នុងគោលដៅផលិតខ្សែភាពយន្ត ឬ វីដេអូ ។
- អ្នកនាំចូល អ្នកនាំចេញផលិតផលភាពយន្ត ឬ វីដេអូ ។
- សេវាករ នៃសេវាកម្មដែលពាក់ព័ន្ធ និងផលិតផលភាពយន្ត ឬ វីដេអូ ។ ៗ/ៗ

**ប្រការ ២ :** កម្រៃអាជ្ញាបណ្ណ និងបន្តសុពលភាពអាជ្ញាប័ណ្ណ ចំពោះផលិតកម្ម សេវាកម្មភាពយន្តវីដេអូ ត្រូវបានកំណត់ដូចតទៅ :

| ប្រភេទអាជ្ញាប័ណ្ណ | តម្លៃ (គិតជារៀល) | |
|---|---|---|
| | រយៈពេល ២ ឆ្នាំ | បន្តសុពលភាព រយៈពេល ១ឆ្នាំ |
| ផលិតកម្មភាពយន្ត វីដេអូ | ២០០.០០០ | ១០០.០០០ |
| ក្រុមហ៊ុននាំចេញ-នាំចូល ភាពយន្ត វីដេអូ | ៨០០.០០០ | ៤០០.០០០ |
| បន្ទប់បញ្ចូលសំឡេង ស្នាដៃភាពយន្ត ឬ ស្នាដៃវីដេអូ | ៥០០.០០០ | ២៥០.០០០ |
| បន្ទប់កាត់ត ដំឡើងរូបភាព ស្នាដៃភាពយន្ត ឬ ស្នាដៃវីដេអូ | ៥០០.០០០ | ២៥០.០០០ |
| រោងបញ្ចាំងភាពយន្ត វីដេអូ ដែលមានកន្លែងអង្គុយតិចជាង ២០០ កន្លែង | ១.០០០.០០០ | ៥០០.០០០ |
| រោងបញ្ចាំងភាពយន្ត វីដេអូ ដែលមានកន្លែងអង្គុយ លើសពី ២០០ កន្លែង | ១.៥០០.០០០ | ៧៥០.០០០ |

**ប្រការ ៣ :** កម្រៃសេវា ពិនិត្យអត្ថបទនិពន្ធរឿងពិស្ដារជាអក្សរសិល្បិ៍ភាសាជាតិមាន ពាក្យសន្ទនា អត្ថបទចម្រៀង និង អត្ថបទនិពន្ធឯកសារ ដើម្បីផ្ដល់ការអនុញ្ញាតថតខ្សែភាពយន្ត ឬថតខ្សែវីដេអូនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះផលិតកម្មភាពយន្ត វីដេអូខ្មែរ និងបរទេស ត្រូវកំណត់ដូចតទៅ :

| ប្រភេទផលិតកម្មភាពយន្ត ឬ វីដេអូ | តម្លៃ (គិតជារៀល) | |
|---|---|---|
| | ខ្មែរ | បរទេស |
| សេវាពិនិត្យខ្លឹមសារអត្ថបទនិពន្ធរឿងពិស្ដារសំរាប់ថតខ្សែភាពយន្ត ឬ វីដេអូរឿង ខ្នាតវែង | ៥០.០០០ | ២០០.០០០ |
| សេវាពិនិត្យខ្លឹមសារអត្ថបទនិពន្ធឯកសារសំរាប់ថតខ្សែភាពយន្ត ឬ វីដេអូឯកសារ | ៣០.០០០ | ១០០.០០០ |
| សេវាពិនិត្យខ្លឹមសារអត្ថបទនិពន្ធរឿងពិស្ដារសំរាប់ថតខ្សែភាពយន្ត ឬ វីដេអូរឿងភាគ ( មួយភាគ រយៈពេលបញ្ចាំងតិចជាង ៤៥នាទី ) | ២៥.០០០ | ១០០.០០០ |
| សេវាពិនិត្យខ្លឹមសារអត្ថបទចម្រៀងសំរាប់ថតខ្សែភាពយន្ត ឬ វីដេអូចម្រៀងកាយវិការ ឬ ខារ៉ាអូខេ | ២៥.០០០ | |

**ប្រការ ៤ :** កម្រៃសេវាពិនិត្យខ្លឹមសាររូបភាព សំរាប់ផ្ដល់ទិដ្ឋាការ ស្នាដៃភាពយន្ត ឬ ស្នាដៃវីដេអូខ្មែរ និងបរទេស ត្រូវបានកំណត់ដូចខាងក្រោម :

**ក- ស្នាដៃភាពយន្ត ឬ ស្នាដៃវីដេអូខ្មែរ**

| ប្រភេទខ្សែភាពយន្ត ឬ វីដេអូរឿង | តំលៃ (គិតជារៀល) |
|---|---|
| ខ្សែភាពយន្ត ឬ វីដេអូរឿង ខ្នាតវែង | ៥០.០០០ |
| ខ្សែភាពយន្ត ឬ វីដេអូរឿង ខ្នាតខ្លី | ៣០.០០០ |
| ខ្សែភាពយន្ត ឬ វីដេអូរឿងភាគ (០១ភាគ) | ១៥.០០០ |
| ខ្សែភាពយន្ត ឬ វីដេអូឯកសារ ខ្នាតវែង | ២៥.០០០ |
| ខ្សែភាពយន្ត ឬ វីដេអូ ឯកសារខ្នាតខ្លី គំនូរជីវចល តុក្កតា ស្ពត | ២០.០០០ |
| ខ្សែភាពយន្ត ឬ វីដេអូ ចម្រៀងកាយវិការ ឬ ខារ៉ាអូខេ មានទម្រង់ជា ឌីវីឌី (DVD) | ៥០.០០០ |
| ខ្សែភាពយន្ត ឬ វីដេអូ ចម្រៀងកាយវិការ ចម្រៀងខារ៉ាអូខេ មានទម្រង់ជាកាសែ្សតវីដេអូ វីស៊ីឌី (VCD) | ៣០.០០០ |

**ខ- ស្នាដៃភាពយន្ត ឬ ស្នាដៃវីដេអូ បរទេស :**

| ប្រភេទខ្សែភាពយន្ត ឬ វីដេអូរឿង | តំលៃ (គិតជារៀល) | | |
|---|---|---|---|
| | សុំរក្សាពាក្យសន្ទនាភាសាដើម | សុំបញ្ចូលពាក្យសន្ទនាជាភាសាខ្មែរ | សុំបញ្ចូលចំណងជើងជាអក្សរខ្មែរ |
| ខ្សែភាពយន្ត ឬ វីដេអូរឿង ខ្នាតវែង | ៥០.០០០ | ២០០.០០០ | ១០០.០០០ |
| ខ្សែភាពយន្ត ឬ វីដេអូរឿង ខ្នាតខ្លី | ៣០.០០០ | ១៥០.០០០ | ៥០.០០០ |
| ខ្សែភាពយន្ត ឬ វីដេអូរឿងភាគ (០១ភាគ) | ២០.០០០ | ១០០.០០០ | ៣០.០០០ |
| ខ្សែភាពយន្ត ឬ វីដេអូឯកសារ ខ្នាតវែង | ៣០.០០០ | ១០០.០០០ | ៣០.០០០ |
| ខ្សែភាពយន្ត ឬ វីដេអូ ឯកសារខ្នាតខ្លី គំនូរជីវចល តុក្កតា ស្ពត | ២០.០០០ | ៨០.០០០ | ២០.០០០ |
| ខ្សែភាពយន្ត ឬ វីដេអូ ចម្រៀងកាយវិការ ឬ ខារ៉ាអូខេមានទម្រង់ជា ឌីវីឌី (DVD) | ៦០.០០០ | | |
| ខ្សែភាពយន្ត ឬវីដេអូ ចម្រៀងកាយវិការ ចម្រៀងខារ៉ាអូខេមានទម្រង់ជាកាសែ្សតវីដេអូ វីស៊ីឌី (VCD) | ៤០.០០០ | | |

**ប្រការ ៥ :** ក្រុមហ៊ុនផលិតកម្ម ឬ រូបវ័ន្តបុគ្គលទាំងឡាយណា ដែលប្រកបអាជីវកម្មមិនបានសុំអាជ្ញាប័ណ្ណ និងមិនមានការត្រួតពិនិត្យ និង ការអនុញ្ញាតពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ឬ ប្រើប្រាស់អាជ្ញាប័ណ្ណផុតសុពលភាព ត្រូវទទួលពិន័យរដ្ឋបាល ហើយត្រូវផាកពិន័យដូចមានចែងក្នុងជំពូកទី ៧ នៃអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការគ្រប់គ្រង ត្រួតពិនិត្យសិល្បៈភាពយន្ត និងវីដេអូ ។

**ប្រការ ៦ :** រាល់ទំរង់បែបបទឯកសារ ដើម្បីស្នើសុំអាជ្ញាប័ណ្ណ អនុញ្ញាតថត សេវាពិនិត្យដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវអនុវត្តតាមនីតិវិធីគ្រប់គ្រង និងត្រួតពិនិត្យសិល្បៈ ភាពយន្តវីដេអូ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

**ប្រការ ៧ :** ចំណូលកម្រៃ អាជ្ញាប័ណ្ណ ភាពយន្ត វីដេអូ និង ការផាកពិន័យដែលបានចែងក្នុងប្រការ ២ ប្រការ ៣

ប្រការ៤ និងប្រការ ៥ ខាងលើត្រូវកំណត់ដូចតទៅ ៖

- ចំណូលនេះត្រូវបានប្រមូលដោយនាយកដ្ឋានសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នឹងត្រូវបង់ ១០០% ចូលរតនាគារជាតិតាមរយៈរដ្ឋទេយ្យករចំណូលរបស់ក្រសួង ។
- ការគ្រប់គ្រងចំណូលនេះត្រូវអនុវត្តតាមនីតិវិធីនៃកិច្ចប្រតិបត្តិការថវិកាទូទៅរបស់រដ្ឋ និងត្រូវបានកត់ត្រាក្នុងជំពូក ៧៣ គណនី ៧៣២ អនុគណនី ៧៣២៨ តាមមាតិកាថវិការដ្ឋនៃច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។
- នាយកដ្ឋានសិល្បៈភាពយន្ត និង ផ្សព្វផ្សាយវប្បធម៌ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវចេញបង្កាន់ដៃទទួលប្រាក់ ឱ្យទៅអតិថិជនដែលបានបង់ប្រាក់ ដោយអនុវត្តតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន ។
- ការប្រមូលចំណូលពីកម្រៃ អាជ្ញាប័ណ្ណ ភាពយន្ត វីដេអូ និងការដាក់ពិន័យ ដែលបានចែងក្នុងប្រការ ២ ប្រការ ៣ ប្រការ ៤ និងប្រការ ៥ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវមានសហការចូលរួមផ្ទៀងផ្ទាត់ និងត្រួតពិនិត្យដោយផ្ទាល់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈត្រូវបូកសរុប និងធ្វើរបាយការណ៍ចំណូលប្រចាំខែ រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានទៀងទាត់ ។

**ប្រការ ៨ :** បទបញ្ញត្តិ ឬប្រកាសទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៩ :** គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ១០:** ប្រកាសនេះមានអានុភាពអនុវត្តគតិយុត្តិ រយៈពេល ៣០ ថ្ងៃក្រោយចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**គាត ឈន់**

រដ្ឋមន្ត្រី
ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

**ហ៊ឹម ឆែម**

**ចម្លងជូន**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលាខេត្ត-ក្រុង
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៩ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ